# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ០១៤ សណណ

ថ្ងៃ ចន្ទ ៨ កើត ខែភទ្របទ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៨

## សារាចរណែនាំ
## ស្តីពី
## នីតិវិធីអនុវត្ត "មាត្រា១៣, មាត្រា១៦, មាត្រា១៧, មាត្រា១៨ និងមាត្រា១៩" នៃអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពី ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ/នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក. ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងតាមសំណូមពរចាំបាច់នៃការងារ

សេចក្តីណែនាំនេះមានគោលបំណងណែនាំអំពីនីតិវិធីអនុវត្តការបង់កម្រៃសេវាសាធារណៈ រយៈពេលចុះវាយតម្លៃ របៀបរបបរៀបចំរបាយការណ៍វាយតម្លៃ និងនីតិវិធីជូនដំណឹងអំពីលទ្ធផលវាយតម្លៃបឋម ស្របតាមតថភាពអភិវឌ្ឍជាក់ស្តែងរបស់សង្គម។

### ១.-អំពីការបង់កម្រៃដាក់ពាក្យស្នើចំណាត់ថ្នាក់សណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ (មាត្រា១៣)

អ្នកដាក់ពាក្យស្នើសុំចំណាត់ថ្នាក់សណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវតែជាបុគ្គលតែមួយដែលឈរឈ្មោះតំណាងឱ្យអាជីវកម្មសណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍នៅក្នុងអាជ្ញាបណ្ណទេសចរណ៍ដែលមានសុពលភាពលើកលែងមានការបញ្ជាក់ផ្ទេរសិទ្ធិត្រឹមត្រូវ។

ពាក្យស្នើសុំចំណាត់ថ្នាក់សណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ត្រូវភ្ជាប់មកជាមួយនូវប្រាក់បង់សេវាសាធារណៈតាមប្រភេទចំណាត់ថ្នាក់ដែលបានស្នើសុំ ដូចខាងក្រោម៖

- ថ្នាក់ផ្កាយ៥ ត្រូវបង់ ៤.០០០.០០០រៀល (បួនលានរៀល)
- ថ្នាក់ផ្កាយ៤ ត្រូវបង់ ៣.០០០.០០០រៀល (បីលានរៀល)
- ថ្នាក់ផ្កាយ៣ ត្រូវបង់ ២.០០០.០០០រៀល (ពីរលានរៀល)
- ថ្នាក់ផ្កាយ២ ត្រូវបង់ ១.០០០.០០០រៀល (មួយលានរៀល)
- ថ្នាក់ផ្កាយ១ ត្រូវបង់ ៨០០.០០០រៀល (ប្រាំបីរយពាន់រៀល)

រាល់ប្រាក់បង់សេវាសាធារណៈសម្រាប់ការស្នើសុំចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍មិនអាចដកវិញបានទេ។

ក្នុងករណីលទ្ធផលនៃការវាយតម្លៃចុងក្រោយបញ្ជាក់ថាអាជីវកម្មនោះទទួលបានចំណាត់ថ្នាក់ក្រោមថ្នាក់ដែលបានស្នើសុំ កម្រៃដែលនៅសល់នឹងត្រូវបង្វែរត្រឡប់ទៅអ្នកស្នើសុំវិញនៅថ្ងៃដែលអ្នកស្នើសុំមកទទួលយកវិញ្ញាបនបត្រ និងផ្លាកចំណាត់ថ្នាក់។

**២.-អំពីរបៀបរបបរៀបចំរបាយការណ៍វាយតម្លៃ (មាត្រា១៦)**

មន្ត្រីវាយតម្លៃត្រូវអនុវត្តរបៀបរបបរៀបចំរបាយការណ៍វាយតម្លៃជំហានដំបូង ដូចខាងក្រោម៖

- របាយការណ៍វាយតម្លៃជំហានដំបូងត្រូវរៀបចំតាមគំរូដូចមានភ្ជាប់ក្នុង**ឧបសម្ព័ន្ធ១**នៃសេចក្តីណែនាំនេះ និងត្រូវមានភ្ជាប់ឯកសារយោងដូចតទៅ៖
    - របាយការណ៍រូបភាព(**ឧបសម្ព័ន្ធ២**)
    - កំណត់ហេតុចុះត្រួតពិនិត្យ(**ឧបសម្ព័ន្ធ៣**)
    - ពាក្យស្នើសុំចំណាត់ថ្នាក់
    - វិញ្ញាបនបត្របញ្ជាក់ចំណាត់ថ្នាក់ឆ្នាំចុងក្រោយ(ក្នុងករណីពាក្យស្នើសុំបន្ត)
- របាយការណ៍វាយតម្លៃជំហានដំបូងត្រូវភ្ជាប់ឯកសារយោងបន្ថែមផ្សេងទៀតករណីដែលមន្ត្រីវាយតម្លៃនិងអ្នកដាក់ពាក្យស្នើសុំ(ឬតំណាង)មិនឯកភាពលើចំនុចមួយ ឬច្រើន នៅក្នុងកំណត់ហេតុត្រួតពិនិត្យ។ ឯកសារបញ្ជាក់ទាំងនោះ អាចជារូបភាពជាក់ស្តែងដែលមានការបរិយាយខាងក្រោម ឬឯកសារផ្សេងទៀតដែលមានចុះសុពលភាពត្រឹមត្រូវ។

**៣.-អំពីនីតិវិធីជូនដំណឹងអំពីលទ្ធផលវាយតម្លៃចំណាត់ថ្នាក់ជំហានដំបូង (មាត្រា១៧ និងមាត្រា១៨)**

មន្ត្រីវាយតម្លៃត្រូវអនុវត្តនីតិវិធីជូនដំណឹងអំពីលទ្ធផលវាយតម្លៃចំណាត់ថ្នាក់ជំហានដំបូងដល់អ្នកដាក់ពាក្យស្នើសុំ ដូចខាងក្រោម៖

- មន្ត្រីវាយតម្លៃត្រូវជូនដំណឹងអំពីលទ្ធផលវាយតម្លៃចំណាត់ថ្នាក់ជំហានដំបូងទៅតាមចំនុចលក្ខណៈវិនិច្ឆ័យនីមួយៗដល់អ្នកដាក់ពាក្យស្នើសុំនៅពេលកំពុងត្រួតពិនិត្យតែម្តង
- ប្រសិនបើអ្នកស្នើសុំមិនឯកភាពចំពោះលទ្ធផលនោះទេ គឺត្រូវតវ៉ាភ្លាមៗតាមនីតិវិធីដូចខាងក្រោម៖
    - **ការតវ៉ាផ្ទាល់មាត់៖** ការតវ៉ាប្រភេទនេះចាត់ទុកជាបានការ លុះត្រាតែភាគីអ្នកស្នើសុំនិងភាគីមន្ត្រីវាយតម្លៃឯកភាពគ្នាកែតម្រូវភ្លាមលើកំណត់ហេតុចុះត្រួតពិនិត្យ

- **ការតវ៉ាដោយរូបភាពសម្អាង:** អ្នកស្នើសុំត្រូវថតរូបចំនុចដែលតវ៉ានោះដោយមានជាប់រូបរបស់ខ្លួនផ្ទាល់ និងត្រូវសរសេរបរិយាយលើកសម្អាងពន្យល់អំពីមូលហេតុ(**ឧបសម្ព័ន្ធ៤**)
- **ការតវ៉ាដោយឯកសារសម្អាង:** អ្នកស្នើសុំត្រូវភ្ជាប់ឯកសារសម្អាងជំទាស់នឹងការសម្រេចរបស់មន្ត្រីវាយតម្លៃ ដោយត្រូវគូសបញ្ជាក់ចំនុចដែលបង្ហាញភស្តុតាងជំទាស់នោះឱ្យបានច្បាស់លាស់(**ឧបសម្ព័ន្ធ៥**)។

**៤.-អំពីនីតិវិធីជូនដំណឹងអំពីលទ្ធផលវាយតម្លៃចំណាត់ថ្នាក់ (មាត្រា១៩)**

គ.វ.ច ត្រូវអនុវត្តនីតិវិធីជូនដំណឹងអំពីលទ្ធផលវាយតម្លៃចំណាត់ថ្នាក់ដល់អ្នកដាក់ពាក្យស្នើសុំ ដូចខាងក្រោម៖

- ការសម្រេចលទ្ធផលវាយតម្លៃចំណាត់ថ្នាក់ដោយ គ.វ.ច ជាសេចក្តីសម្រេចចុងក្រោយនិងបិទផ្លូវតវ៉ា
- មន្ត្រីវាយតម្លៃ អាចចុះប្រតិបត្តិការបានតែក្នុងលក្ខខណ្ឌដែល គ.វ.ច.រាជធានីខេត្តបានចាត់តាំងជាលាយលក្ខណ៍អក្សរ
- ជាគោលការណ៍ មន្ត្រីវាយតម្លៃត្រូវចុះត្រួតពិនិត្យនិងវាយតម្លៃនៅក្នុងអំលុងពេលយ៉ាងយូរ **០១ថ្ងៃ** បន្ទាប់នៃកាលបរិច្ឆេទសម្រេចចាត់តាំងសមាសភាពមន្ត្រីវាយតម្លៃ
- មន្ត្រីវាយតម្លៃ ត្រូវចុះវាយតម្លៃដោយគោរពឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌដូចខាងក្រោម៖
  - មានឯកសណ្ឋានត្រឹមត្រូវតាមការណែនាំរបស់ គ.វ.ច.
  - មានពាក់ស្លាកសម្គាល់ជាមន្ត្រីវាយតម្លៃ(**មានសុពលភាព**)
  - មានភ្ជាប់បង្ហាញជូនអាជីវកម្មនូវលិខិតបង្គាប់ការ ឬលិខិតចាត់តាំងសមាសភាពដែលមានបញ្ជាក់ថ្ងៃខែឆ្នាំចុះត្រួតពិនិត្យច្បាស់លាស់
- ក្នុងអំលុងពេលវាយតម្លៃ មន្ត្រីវាយតម្លៃត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់អ្នកវាយតម្លៃ និងមិនត្រូវ៖
  - អត្តនោម័តនាំយកមន្ត្រី ឬបុគ្គលផ្សេងក្រៅអំពីសមាសភាពដែលបានចាត់តាំងចូលរួមក្នុងកិច្ចវាយតម្លៃឡើយ
  - លើកបង្ហាញប្រៀបធៀបលក្ខណៈសម្បត្តិសណ្ឋាគារ ឬសេវាកម្មស្នាក់នៅផ្សេងទៀត
  - ចែករំលែកព័ត៌មានផ្ទៃក្នុងរបស់អង្គភាព
  - បង្កលក្ខណៈឱ្យអាជីវកម្មដាក់ពាក្យស្នើសុំអាចយល់ដឹងអំពីចំណាត់ថ្នាក់របស់ខ្លួនជាមុន
- ការវាយតម្លៃមិនត្រូវមានរយៈពេលលើសពី **០៤ម៉ោងក្នុង១លើក**
- ប្រធានក្រុមវាយតម្លៃត្រូវកោះប្រជុំសមាជិករបស់ខ្លួនភ្លាមៗ(**ប្រជុំសម្ងាត់**) បន្ទាប់ពីបញ្ចប់ការវាយតម្លៃដើម្បីពិភាក្សាអនុម័តលើពិន្ទុ និងចុះហត្ថលេខាលើតារាងត្រួតពិនិត្យ (**ដូចមានក្នុងឧបសម្ព័ន្ធ៦**)
- ក្រោយកិច្ចប្រជុំសម្ងាត់ សមាជិកក្រុមចុះវាយតម្លៃទាំងអស់ត្រូវជួបប្រជុំជាមួយតំណាងអាជីវកម្មដែលដាក់ពាក្យដើម្បីពិនិត្យ និងឯកភាពលើតារាងត្រួតពិនិត្យ រួចចុះហត្ថលេខាលើតារាងត្រួតពិនិត្យនោះផងដែរ

- បន្ទាប់ពីបញ្ចប់ការវាយតម្លៃ ប្រធានក្រុមចុះវាយតម្លៃត្រូវប្រគល់ឯកសារត្រឡប់មកលេខាធិការវិញ។ ឯកសារដែលត្រូវប្រគល់ រួមមាន៖
    - ឯកសារពាក្យសុំ (ច្បាប់ដើម)
    - តារាងវាយតម្លៃដែលមានហត្ថលេខារបស់សមាជិកក្រុមចុះវាយតម្លៃទាំងអស់ និងតំណាងអាជីវកម្ម (ច្បាប់ដើម)
    - របាយការណ៍វាយតម្លៃ (**ដូចមានក្នុងឧបសម្ព័ន្ធ៧**) ជាឯកសារសំណៅរឹង និងសំណៅទន់
    - របាយការណ៍រូបភាព (**ដូចមានក្នុងឧបសម្ព័ន្ធ២**) ជាឯកសារសំណៅទន់ ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល៖**
-សាលារាជធានីខេត្ត
**"ដើម្បីជូនជ្រាប"**
-មន្ទីរទេសចរណ៍រាជធានីខេត្ត
**"ដើម្បីមុខការអនុវត្ត"**
-ឯកសារ-កាលប្បវត្តិ